**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ករណីអាជ្ញាធរថៃ ចុះត្រួតពិនិត្យការប្រើប្រាស់ពលករបរទេសមិនមានឯកសារគ្រប់គ្រាន់

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេស ប្រជាពលរដ្ឋដែលមានបំណងទៅធ្វើការនៅប្រទេសថៃ ជ្រាបថា ក្នុងប្រតិបត្តិការចុះត្រួតពិនិត្យការប្រើប្រាស់កម្លាំងពលកម្មបរទេសនៅតាមសហគ្រាស ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ នេះ អាជ្ញាធរថៃ បានឃាត់ខ្លួនពលករបរទេសមិនមានឯកសារគ្រប់គ្រាន់ចំនួន ២៤០នាក់ ក្នុងនោះ មានពលករកម្ពុជាចំនួន ៨នាក់ផងដែរ។

ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមក្រើនរំលឹកដល់ប្រជាពលរដ្ឋដែលមានបំណងស្វែងរកការងារធ្វើនៅប្រទេសថៃដោយស្របច្បាប់ ជ្រាបថា ការ**មានលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស** (TD) **ឬលិខិតឆ្លងដែនដែលមានទិដ្ឋាការទេសចរណ៍ នោះគ្រាន់តែអាចឆ្លងដែនតែប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើការងារដោយស្របច្បាប់នៅប្រទេសថៃបាននោះទេ។** ដើម្បីក្លាយជាពលករស្របច្បាប់តាមប្រព័ន្ធអនុស្សរណៈនៃការយោគយល់គ្នារវាងប្រទេសកម្ពុជា ថៃ (MOU) បងប្អូនប្រជាពលរដ្ឋត្រូវមានឯកសារ ដូចជា លិខិតឆ្លងដែនឬលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) បណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ទិដ្ឋាការការងារ បណ្ណអនុញ្ញាតការងារដែលមានសុពលភាព និងធ្វើការជាមួយនិយោជកតាមបណ្ណអនុញ្ញាតការងារ។ ករណីប្រជាពលរដ្ឋនៅតាមខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ប្រើប្រាស់បណ្ណព្រំដែន ដើម្បីទៅធ្វើការតាមរដូវកាលដោយស្របច្បាប់ បងប្អូនត្រូវមាននិយោជកត្រឹមត្រូវ បណ្ណអនុញ្ញាតការងារ និងធ្វើការនៅកន្លែងដែលអនុលោមទៅតាមគោលការណ៍និងច្បាប់របស់ខេត្តជាប់ព្រំដែន។

ដើម្បីបង្ការនូវការឆបោករបស់ជនខិលខូច ឬការឆ្លងដែនរកការងារធ្វើនៅប្រទេសថៃដោយប្រើប្រាស់ឯកសារមិនគ្រប់គ្រាន់ បងប្អូនប្រជាពលរដ្ឋអាចសាកសួរព័ត៌មានបន្ថែម អំពីឱកាសការងារនៅបរទេសតាមរយៈប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ឬទូរស័ព្ទលេខ ០៩៧ ៩២០ ២០២៣/ ០៨៩ ៩៥៧ ៧៨៩/ ០១៥ ៧៨៦ ៩៨៨ ឬទំនាក់ទំនងមកកាន់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមាននៅក្នុងគេហទំព័រ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនបង្កើនការប្រុងប្រយ័ត្នខ្ពស់ និងរៀបចំឯកសារឱ្យបានគ្រប់គ្រាន់ទៅតាមច្បាប់មុនចេញដំណើរទៅធ្វើការនៅប្រទេសថៃ។

ថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩